ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមការងារចុះមូលដ្ឋាន
ស្រុកបាត់ី ខេត្តតាកែវ

**សូមជម្រាបជូន**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ចុះមូលដ្ឋានឃុំទាំង៩ ក្នុងស្រុកបាត់ី**

**កម្មវត្ថុ៖** ស្តីពីការចូលរួមបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ នៅតាមវត្តនានា ស្ថិតក្នុងឃុំទាំង៩ ក្នុងស្រុកបាត់ី។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិកក្រុមការងារឃុំទាំង៩ ក្នុងស្រុកបាត់ី មេត្តាជ្រាបថា ដើម្បីចូលរួមប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌទៅតាមគន្លងប្រពៃណីព្រះពុទ្ធសាសនានៅឆ្នាំនេះ ដែលចាប់ផ្តើមពីថ្ងៃ១រោច ដល់១៥រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២១ ខ្ញុំសូមអំពាវនាវ ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តារួមសាមគ្គីជាមួយសប្បុរសជន និងពុទ្ធបរិស័ទចំណុះជើងវត្ត ម្ចាស់ការរៀបចំចាត់ចែងពិធីនេះ នៅតាមវត្តនានាក្នុងមូលដ្ឋានឃុំ រៀងៗខ្លួន។

ចំពោះរូបភាព កម្មវិធី និងកាលបរិច្ឆេទ នៃការប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌឆ្នាំនេះ គឺអាស្រ័យដោយការសម្រេចរបស់ក្រុមការងារឃុំនីមួយៗ ដើម្បីជានាសុវត្ថិភាព សុខុមាលភាព ជៀសផុតពីជំងឺកូវីដ-១៩ ដោយត្រូវចាក់វ៉ាក់សាំង និងប្រកាន់ខ្ជាប់នូវវិធានការ "៣ការពារ និង ៣កុំ"។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តាជ្រាប និងចូលរួមពិធីបុណ្យឱ្យបានច្រើនកុះករដើម្បីចាប់មគ្គផល និងទទួលកុសលផលបុណ្យទៅតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅបំផុតពីខ្ញុំ។ ៚

ថ្ងៃ សៅរ៍ ៨ កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០២១

**ប្រធានក្រុមការងារចុះមូលដ្ឋានស្រុកបាត់ី** ~~

**ព្រុំ សុខា**